# សុន្ទរកថា
# លោក គង់ ឆេង ប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តកណ្តាល
# និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ
# នៃសម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា
# នៅក្នុងពិធីបើកកិច្ចប្រជុំពិភាក្សាលើ "កម្រងសំនួរអំពីអំពើហឹង្សាយេនឌ័រ"
# រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២

សូមគោរព

- លោកស្រីនាយិកាប្រតិបត្តិវិទ្យាស្ថានបើកទូលាយ
- លោក លោកស្រី ជាមេឃុំ ចៅសង្កាត់ ចៅសង្កាត់រង និងសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ មកពីរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបងនិង ខេត្តកំពង់ធំ
- លោក លោកស្រីតំណាងអង្គការមិនមែនរដ្ឋភិបាល និងវិទ្យាស្ថានស្រាវជ្រាវ

ថ្ងៃនេះ ខ្ញុំបាទមានកិត្តិយស និងមានសេចក្តីរីករាយជាអនេកដោយមានឱកាសបានមកចូលរួមថ្លែងសុន្ទរកថាបើក**កិច្ចប្រជុំពិភាក្សាលើ "កម្រងសំនួរអំពីអំពើហឹង្សាយេនឌ័រ"** ដែលបានរៀបចំដោយអង្គការវិទ្យាស្ថានបើកទូលាយ ដោយសហការជាមួយសម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា។ កន្លងមក សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានសហការជាមួយអង្គការវិទ្យាស្ថានបើកទូលាយ ដើម្បីបើកវគ្គបណ្តុះបណ្តាលមួយចំនួនដល់សមាជិកក្រុមប្រឹក្សាសង្កាត់នៅរាជធានីភ្នំពេញអំពីសិទ្ធិទទួលព័ត៌មាន។ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ដែលតំណាងឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេស នឹងខិតខំប្រឹងប្រែងស្វែងរកដៃគូ ជាពិសេសនឹងបន្តកិច្ចសហការជាមួយ អង្គការវិទ្យាស្ថានបើកទូលាយបន្ថែមទៀត ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមបណ្តាខេត្តផងដែរ ក្នុងបំណងលើកកំពស់ការយល់ដឹងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អំពីសារៈសំខាន់នៃការចែករំលែកព័ត៌មានដល់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។ ខ្ញុំសូមឆ្លៀតយកឱកាសនេះដើម្បីថ្លែងអំណរគុណដល់អង្គការវិទ្យាស្ថានបើកទូលាយ ដែលបានយកចិត្តទុកដាក់ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងដល់លោកស្រីអស់លោកជាចៅសង្កាត់ ឬជា សមាជិកក្រុមប្រឹក្សាសង្កាត់ ដែលបានចំណាយ

ពេលវេលា ដ៏មានតំលៃដើម្បីមកចូលរួមក្នុងការបណ្តុះបណ្តាលក្នុងពេលកន្លងមក ក៏ដូចជានៅក្នុងការពិភាក្សាលើកម្រង សំនួរអំពីអំពើហឹង្សាយេនឌ័រនាថ្ងៃនេះ។

លោកស្រី អស់លោកជាទីរាប់អាន

ខ្ញុំជឿជាក់ថា កិច្ចប្រជុំពិភាក្សាលើកម្រងសំនួររយៈពេលមួយថ្ងៃនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីឆ្លុះបញ្ចាំងពីកិច្ចការដែលបានអនុវត្តកន្លងមកទាក់ទង នឹងការលើកកម្ពស់សិទ្ធិស្ត្រីក្នុងការចូលរួមកិច្ចអភិវឌ្ឍនៅមូលដ្ឋាន ជាពិសេសនៅក្នុងការធ្វើសេចក្តីសំរេចចិត្តដែលមានផលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ ដូច្នេះ ខ្ញុំបាទស្នើសុំឲ្យលោកស្រី អស់លោកទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចពិភាក្សានេះ ចូលរួមបញ្ចេញមតិយោបល់ឲ្យបានទូលំទូលាយ ដើម្បីធ្វើឲ្យបញ្ជីសំនួរនេះកាន់តែមានភាពល្អប្រសើរឡើង។

ជាថ្មីម្តងទៀត នាងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការវិទ្យាស្ថានបើកទូលាយដែលបានសហការជាមួយសម្ព័ន្ធភាពជាតិឃុំ សង្កាត់ក្នុងការរៀបចំកិច្ចប្រជុំនេះឡើង និងសូមជូនពរឲ្យការពិភាក្សាទទួលបានលទ្ធផលតាមការរំពឹងទុក និងសូមប្រកាសបើកកិច្ចពិភាក្សានេះ ចាប់ពីពេលនេះតទៅ។

សូមអរគុណ